**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករទូរគមនាគមន៍កម្ពុជា**

លេខ :....១១១៥.......ន.ទ.ក.

# ជម្រាបជូន

## ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី

## អគ្គនាយក ប្រធានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័តទាំងអស់

**កម្មវត្ថុ៖** ករណីការស្នើសុំផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនទូរស័ព្ទចល័ត អចល័តទាំងអស់។

**យោង៖**
- ច្បាប់ស្តីពីទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា។
- លិខិតលេខ០២៧៦ ន.ទ.ក. ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងសកម្មភាពឃោសនាពាណិជ្ជកម្មរបស់ក្រុមហ៊ុនទូរស័ព្ទចល័ត។
- លិខិតលេខ១០៦៩ ន.ទ.ក. ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបញ្ឈប់នូវកម្មវិធីផ្សព្វផ្សាយរូបភាព (ការប្តូរលុយ) និងខ្លឹមសារនៃការឃោសនាពាណិជ្ជកម្មរបស់បណ្តាប្រតិបត្តិករទូរស័ព្ទដែលកំពុងធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ **និយ័តករទូរគមនាគមន៍កម្ពុជា(ន.ទ.ក.)** សូមជម្រាបជូនដំណឹងដល់គ្រប់ប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័ត អចល័តទាំងអស់ ជ្រាបថា៖ ដើម្បីធានាបាននូវសកម្មភាពប្រកួតប្រជែងប្រកបដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព និងដើម្បីជៀសវាងផលប៉ះពាល់ដល់ផលប្រយោជន៍អ្នកប្រើប្រាស់ ក៏ដូចជាចំណូលថវិកាជាតិប្រចាំឆ្នាំពីវិស័យទូរគមនាគមន៍ និយ័តករទូរគមនាគមន៍កម្ពុជា សូមធ្វើការណែនាំជាថ្មីដល់គ្រប់ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័តទាំងអស់ ឱ្យបានជ្រាបថា៖

១. រាល់ការផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទត្រូវស្នើសុំការអនុញ្ញាតពី និយ័តករទូរគមនាគមន៍កម្ពុជាជាមុនសិន។

២. រាល់ពាក្យស្នើសុំផ្សព្វផ្សាយពាណិជ្ជកម្ម (Application Form for Promotion) ត្រូវមានចុះហត្ថលេខាដោយអគ្គនាយកក្រុមហ៊ុន រឺនាយកប្រតិបត្តិ និងត្រូវមានបោះត្រា (Official Stamp) ជាផ្លូវការ និងរាល់ខិតប័ណ្ណគំរូ (leaflet) ត្រូវមានបោះត្រាក្រុមហ៊ុនផងដែរ។

៣. មុនពេលទទួលបានការយល់ព្រមពី និយ័តករទូរគមនាគមន៍កម្ពុជា មិនត្រូវបោះពុម្ព ឬធ្វើការផ្សព្វផ្សាយលើបណ្តាញសង្គម ឬមធ្យោបាយណាមួយឡើយ។

៤. រាល់គម្រោងនីមួយៗ ការលើកស្លាក ខិតប័ណ្ណផ្សព្វផ្សាយគម្រោងនីមួយៗ ត្រូវមានព័ត៌មានលំអិតច្បាស់លាស់អំពីវិធីសាស្ត្រភ្ជាប់សេវា (Subscribe Code) វិធីសាស្ត្រផ្តាច់សេវា (Unsubscribe Code) ដល់អ្នកប្រើប្រាស់ ព្រមទាំងសេវាកម្ម Auto Renew ។

៥. ត្រូវធានាគុណភាពសេវាឱ្យបានតាមស្តង់ដាកំណត់។

៦. ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីការប្តូរប្រាក់ ឬបន្ថែមទឹកប្រាក់(Promotion Rate) មិនត្រូវមានលក្ខណៈភូតកុហកអតិថិជន និង/ឬលក់ក្រោមថ្លៃដើម និងសូមភ្ជាប់មកនូវតារាងគណនាថ្លៃដើម។

៧. ត្រូវគោរពនូវរាល់ច្បាប់ បទប្បញ្ញត្តិជាធរមាន។

នៅពេលដែលក្រុមហ៊ុនបានបំពេញនូវលក្ខខណ្ឌខាងលើ ទើបនិយ័តករទូរគមនាគមន៍កម្ពុជា ពិចារណាលើការស្នើសុំអនុញ្ញាតធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់រូបភាពនៃក្រុមហ៊ុនរបស់ ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ទាំងអស់។

និយ័តករទូរគមនាគមន៍កម្ពុជា សង្ឃឹមថា **ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អគ្គនាយក** ប្រធានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័តទាំងអស់ នឹងយកចិត្តទុកដាក់សហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍។

សូម **ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អគ្គនាយក** ប្រធានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័តទាំងអស់ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ថ្ងៃសុក្រ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៩
**ប្រធាន**

ម៉ុង ចរិយា

**ចម្លងជូនៈ**
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីគោរពជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ